- ខាងលិចទល់នឹងត្រពាំងភ្លាំង ស្រុកឈូក ខេត្តកំពត ។

- ខាងកើតទល់នឹងឃុំស្រែចែង ឃុំស្វាយអញ្ចើត ឃុំត្រពាំងរាំង ស្រុកជុំគីរី ខេត្តកំពត

**មាត្រា ៣.**- - ទីតាំងរដ្ឋបាលឃុំត្រពាំងភ្លាំង ស្ថិតនៅក្នុងភូមិកោះស្លា ។

- ទីតាំងរដ្ឋបាលឃុំតាកែន ស្ថិតនៅក្នុងភូមិមនោសុខ ។

**មាត្រា ៤.**- បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.**- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួង មហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងគ្រប់ រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែមេសា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

---

## អនុក្រឹត្យលេខ ៣៧ អ.ន.ក្រ.បក

## ស្ដីពី

## ការបង្កើតឃុំអូរស្វាយ ចំណុះស្រុកសំរោង ខេត្តឧត្តរមានជ័យ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករាឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៩/០៧ ចុះថ្ងៃទី ២៨ខែ មករាឆ្នាំ ១៩៩៩ ស្តីពីការបង្កើតខេត្តឧត្តរមានជ័យ

- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា១.-** ត្រូវបានបង្កើតឃុំអូរស្មាច់ ចំណុះស្រុកសំរោង ខេត្តឧត្តរមានជ័យដោយកាត់យកភូមិសាស្ត្រមួយចំណែករបស់ឃុំកូនក្រៀល ស្រុកសំរោង ខេត្តឧត្តរមានជ័យ ។

**មាត្រា២.-** ឃុំអូរស្មាច់ មានព្រំប្រទល់រដ្ឋបាល :

- ខាងលិច ខាងកើត និងខាងជើងទល់នឹងព្រំប្រទល់ប្រទេសថៃ ។
- ខាងត្បូងទល់នឹងឃុំកូនក្រៀល ។

**មាត្រា៣.-** ទីតាំងរដ្ឋបាលឃុំអូរស្មាច់ ស្ថិតនៅក្នុងភូមិអូរស្មាច់ ។

**មាត្រា៤.-** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៥.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួង មហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែមេសា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

---

**អនុក្រឹត្យលេខ ១៣៨ អ.ន.ក្រ.តត**

**ស្តីពី**

**ការតែងតាំងមន្ត្រីរាជការ**

---

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា